STREAM

ឆ្នាំទី១ លេខ៣ ខែ កក្កដា-កញ្ញា ២០០២

**Support to Regional Aquatic Resources Management**

**គំរោងជួយគ្រប់គ្រងធនធានវារីជាតក្នុងតំបន់**

# ទស្សនាវដ្តី STREAM

**ការទំនាក់ទំនង និង ការរៀនសូត្រពីជីវភាពរស់នៅរបស់អ្នកនេសាទ និង កសិករ**

គំរោងត្រូវបានការជួយឧបត្ថម្ភដោយ AusAID, DFID, FAO, NACA និង VSO

# មាតិកា


| អត្ថបទ | ទំព័រ |
|---|---|
| ពីអ្នកប្រើប្រាស់ធនធានទៅជាអ្នកគ្រប់គ្រងធនធានៈ រឿងរ៉ាវផ្លាស់ប្តូរសំខាន់មួយ | ១ |
| Ruperto Aleroza បានប្រាប់ទៅ Jocel Pangillinan Ronet Santos | |
| ការផ្លាស់ប្តូរសំខាន់ដោយក្រុមសិក្សាពីការចិញ្ចឹមជីវិតខេត្តរបស់ប្រទេសកម្ពុជា | ៤ |
| Bun Hay Cheng, Tan Someth Bunwhat, Mey Chanthou and Bun Puthy | |
| ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទក្នុងរយៈពេលមួយឆ្នាំ | ៧ |
| Matt Fox | |
| ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទបើកការរកស៊ី | ១០ |
| Louise Mackeson-Sandbach | |
| ការជាប់ពាក់ពន្ធ័នៃស្ថាប័ន និង អ្នកជាប់ពាក់ពន្ធ័ក្នុងការគ្រប់គ្រង និង អភិវឌ្ឍន៍វិស័យវារីវប្បកម្ម | ១២ |
| M Krishnan និង Pratap S Birthal | |
| ផលិតកម្មកូនត្រីពូជសំរាប់វារីវប្បកម្មនៅភាគអគ្នេយ៏នៃប្រទេសកម្ពុជាៈ ការធ្វើវិមជ្ឈការ-ផ្លូវដែលត្រូវដើរ? | ១៥ |
| Olivier Delahaye Gamucci, Graham C Mair Harvey Demaine | |
| ពតិមានពីទស្សនាវដ្តីរបស់ **STREAM** | ១៨ |
| ពតិមានពី **STREAM** | ២០ |

**កំណត់ចំណាំៈ**

អត្ថបទសំខាន់ៗរបស់ទស្សនាវដ្ដី STREAM នៅលេខនេះមាន៤ អត្ថបទដែលទាក់ទងនឹងប្រទេសកម្ពុជា ដែលផ្ដោតជាសំខាន់ទៅលើយុទ្ធវិធី "ការផ្លាស់ប្ដូរសំខាន់" ដើម្បីធ្វើការត្រួតពិនិត្យ និង វាយតំលៃ និង រៀបរាប់ពី រឿងរ៉ាវផ្ទាល់ខ្លួន និង របស់អង្គការ។ ទស្សនាវដ្ដី STREAM លេខ៣នេះបានរៀបរាប់រឿងរ៉ាវដោយលោក Ruperto Aleroza ដែលជាអ្នកនេសាទជនជាតិហ្វីលីពីនម្នាក់ដែលបានសរសេរពីទស្សនៈកិច្ចសិក្សារបស់គាត់នៅប្រទេសថៃ ដែលឧបត្ថម្ភដោយ SPARK។
បីអត្ថបទបន្ទាប់មកទៀតគឺបានមកពីសហការីរបស់យើងនៅប្រទេសកម្ពុជាដែលជាដៃគូរធ្វើការនៅការិយាល័យ អភិវឌ្ឍន៍សហគមន៍នេសាទ (CFDO) នៃនាយកដ្ឋានជលផល, កម្មវិធី SCALE និង មន្ត្រីការិយាល័យជលផលខេត្ត និង មន្ទីរកិច្ចការនារីខេត្តចំនួន ៣ នាក់ និង STREAM។ លោក ប៊ុន ហាក់ឆេង លោក តាន់ សុមេតប៊ុនវឌ្ឍ លោកស្រី ម៉ី ចាន់ធូ និង លោកស្រី ប៊ុន ពុទ្ធីបានពន្យល់តើ "ការផ្លាស់ប្ដូរសំខាន់" ត្រូវបានក្រុមសិក្សាពីការចិញ្ចឹមជីវិតយកទៅអនុវត្តយ៉ាងដូចម្ដេច។ លោក Matt Fox និង កញ្ញា Louise Mackeson-Sandbach ដែលអ្នកទាំងពីរជាអ្នកស្ម័គ្រចិត្តធ្វើការនៅ CFDO បានបង្ហាញពីការរីកចំរើនរបស់ការិយាល័យ។ លោក Mattបានបង្ហាញពីរូបភាពនៃទន្លេនៅប្រទេសកម្ពុជា ចំណែកឯកញ្ញា Louiseបង្ហាញរូបភាពពីរដែលមានអត្ថន័យយ៉ាងជ្រាលជ្រៅ។
អត្ថបទទី៥ លោក M Krishman និង Pratap S Birthal ពិនិត្យមើលពីតួនាទីរបស់សហគមន៍ក្នុងវារីវប្បកម្មសមុទ្រនៅប្រទេសឥណ្ឌា។ អត្ថបទចុងក្រោយយើងត្រលប់ទៅប្រទេសកម្ពុជាវិញជាមួយនិងរបាយការណ៍ពីការចុះអង្កេត ផលិតកម្មកូនត្រីពូជ និង ការធ្វើវិមជ្ឈការដែលសរសេរដោយលោក Olivier Delahaye Gamucci, Graham C Mair និង Harvey Demaine នៃវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី។
យើងមានសេចក្ដីរីករាយជំរាបជូនអស់លោកអ្នកថា STREAM មានទស្សនាវដ្ដីជាភាសាខ្មែរ និង វៀតណាម ហើយកំពុងបោះពុម្ពដើម្បីចែកចាយឱ្យដៃគូររបស់យើងនៅប្រទេសកម្ពុជា និង វៀតណាម ជាពិសេស សហការីដែលធ្វើការនៅតាមខេត្ត។ ទស្សនាវដ្ដីជាភាសាផ្សេងទៀតអាចរកបានតាមរយៈបណ្ណាល័យ STREAM នៅ លើ Website។ សូមរង់ចាំទស្សនាវដ្ដីជាភាសានេប៉ាល់ដែលនឹងមកដល់ក្នុងពេលឆាប់ៗនេះ។
យើងនឹងបន្តរាយការណ៍លើរាល់ការទំនាក់ទំនងផ្សេងៗដែលយើងមានជាមួយអ្នកអានរបស់យើង។ លោក Ashis Kumar ជាជនជាតិឥណ្ឌា និង លោក M E Azim ជនជាតិបង់ក្លាដែស អ្នកទាំងពីរជាអ្នកសរសេរអត្ថបទនៅក្នុងទស្សនាវដ្ដី STREAM លេខ២ បានឆ្លើយឆ្លងគ្នាតាមរយៈអ៊ីមែលពីការងារស្រាវជ្រាវលើការចិញ្ចឹមត្រីដែលប្រើ periphyton និង សក្ដានុពលរបស់វាដើម្បីយកទៅអនុវត្តនៅក្នុងប្រទេសឥណ្ឌា។ អ៊ីមែលរបស់លោក Ashish : < ashishkumar_1in@yahoo.com។

សូមលោកអ្នកអានដោយក្ដីរីករាយ

លោក Graham Haylor នាយកគំរោង STREAM

លោក William Savage បណ្ណាធិការទស្សនាវដ្ដី STREAM

# ពីអ្នកប្រើប្រាស់ធនធានទៅជាអ្នកគ្រប់គ្រងធនធានៈ   រឿងរ៉ាវផ្លាស់ប្តូរសំខាន់មួយ[1]

ដោយលោក Ruperto Aleroza បានប្រាប់ទៅ

លោក Jocel Pangilian និង លោក Ronet Santos

## អ្នកនេសាទ  ប្រធានសហគមន៍  និង  នាយកអង្គការ

ខ្ញុំឈ្មោះ Ka Uper អាយុ ៤៨ ឆ្នាំ ជាអ្នកនេសាទ និង ជាប្រធានសហគមន៍ ។ ថ្វីត្បិតតែខ្ញុំបានរៀនចប់ថ្នាក់បឋមសិក្សា ប៉ុន្តែខ្ញុំបានក្លាយទៅជាសមាជិកក្រុមប្រឹក្សាភូមិ Encarnacion barangay ដែលជាភូមិមួយនៅជាប់មាត់សមុទ្រនៃប្រទេសហ្វីលីពីន ចាប់ពីឆ្នាំ ១៩៩១ រហូតដល់ ១៩៩៣ ។ ក្នុងឆ្នាំ ១៩៩២ ខ្ញុំបានក្លាយជាសមាជិកនៃ SAMMACA (សមាគមន៍អ្នកនេសាទគ្រួសារនៃ Calatagan) ដែលជាអង្គការមួយបានមកពីកិច្ចខិតខំប្រឹងប្រែងរៀបចំសហគមន៍របស់អង្គការ CERD (មជ្ឈមណ្ឌលដើម្បីអភិវឌ្ឍន៍ធនធាន និង ការផ្តល់អំណាច) ដែលផ្តោតជាសំខាន់គឺជួយដល់ពួកអ្នកនេសាទគ្រួសារ ។ ឥឡូវនេះខ្ញុំជានាយកនៃ SAMMACA ។ អង្គការបានរីកចំរើនហើយបានក្លាយទៅជាសហពន្ធ័ដែលមាន ១០ សហគមន៍នៅក្នុងភូមិចំនួន ៩ នៃ Calatagan ដែលមានសមាជិកជាង ៧00 នាក់ ។

## រៀនសូត្រ  និង  ចែករំលែកបទពិសោធពីការគ្រប់គ្រងធនធាន

កាលពីឆ្នាំទៅមិញ ខ្ញុំត្រូវបានគេជ្រើសរើសឱ្យចូលរួមក្នុងទស្សនៈកិច្ចសិក្សាមួយនៅប្រទេសថៃក្នុងចំណោម ប្រធានសហគមន៍ចំនួន ១២ អង្គការមិនមែនរដ្ឋាភិបាល មន្ត្រីមូលដ្ឋាននៃប្រទេសហ្វីលីពីន ឥណ្ឌូនេស៊ី និង ថៃ ចាប់ពីថ្ងៃទី ១-១៥ សីហា ដើម្បីរៀនពីរបៀបសហគមន៍ចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិ[2] ។ នៅភាគខាងជើងនៃប្រទេសថៃ ខ្ញុំសង្កេតឃើញពីរបៀបដែលបណ្តាញកសិករនៅភាគខាងជើង ចូលរួមនៅក្នុងការគ្រប់គ្រងទីជំរាល (Watershed) នៅស្រុក Samoeng នៅជិតខេត្តឈៀងម៉ៃ ។ ខ្ញុំបានជួបលោក Pisit Charnoh[3] ខ្ញុំបានរៀន និង ផ្លាស់ប្តូរបទពិសោធជាមួយអ្នកនេសាទគ្រួសារនៅភាគខាងជើងប្រទេសថៃពីរបៀបគ្រប់គ្រងទីជំរកត្រីស្តារតំបន់ព្រៃកោងកាងឡើងវិញ និង ចរចារជាមួយអ្នកប្រើប្រាស់ផ្សេងទៀតពីកន្លែងនេសាទ ។



*លោក Ka Uper (នៅខាងស្តាំដៃ ជួរទីពីរ កំពុងសរសេរ) នៅពេលធ្វើដំណើរទស្សនៈកិច្ចសិក្សានៅប្រទេសថៃ*

---

[1] អត្ថបទនេះគឺជាការសរសេរឡើងវិញក្នុងចំណោមអត្ថបទទាំងឡាយដែលបានចុះនៅក្នុងទស្សនាវដ្តី SPARK លេខ ៩ ចុះខែ មិថុនា ២00២

[2] ប្រធានសហគមន៍ មន្ត្រីមូលដ្ឋាន និង ប្រធានអង្គការមិនមែនរដ្ឋាភិបាលជាង ៥២ អ្នកត្រូវបានគេជ្រើសរើចឱ្យចូលរួមនៅក្នុងទស្សនៈកិច្ចសិក្សានេះកាលពីឆ្នាំទៅមិញ

[3] ជាអ្នកទទួលបានពានរង្វាន់មាសផ្នែកបរិស្ថាន ចំពោះការងាររបស់គាត់ដែលបានថែរក្សាប្រពន្ធ័អេកូឡូស៊ីរបស់ប្រទេសថៃដើម្បីជួយដល់ការចិញ្ចឹមជីវិតរបស់ពួកគាត់

ការទំនាក់ទំនងរបស់ខ្ញុំជាមួយនិងអ្នកនេសាទគ្រួសារផ្សេងៗទៀតមកពីប្រទេសថៃ និង ឥណ្ឌូនេស៊ី តាមរយៈទស្សនៈកិច្ចសិក្សា និង សិក្ខាសាលាថ្នាក់តំបន់ក្រោមការជួយឧបត្ថម្ភរបស់SPARK បានធ្វើឱ្យខ្ញុំដឹងថាគន្លឹះសំខាន់ក្នុងការគ្រប់គ្រងធនធានសាធារណៈ (ឧទា. កន្លែងនេសាទប្រើប្រាស់ដោយអ្នកដែលមិនមែនជាអ្នកនេសាទ ដូចជា អ្នករកស៊ីខាងទេសចរ និង អ្នករកស៊ីតាមសមុទ្រ) គឺត្រូវមានការចូលរួមពីគ្រប់អ្នកប្រើប្រាស់ទាំងអស់នៅក្នុងការសំរេចចិត្តលើ ថាតើត្រូវដាក់បទបញ្ញត្តិអ្វីខ្លះទាក់ទងនឹងការប្រើប្រាស់ធនធាន និង ពីរបៀបអនុវត្តនូវបទបញ្ញត្តិទាំងនេះ។ ខ្ញុំគិតថាជាការសំខាន់ណាស់ដែលអ្នកនេសាទគ្រួសារដែលជីវភាពពឹងផ្អែកជាសំខាន់លើការនេសាទ និង អ្នកប្រើប្រាស់ធនធានទាំងអស់ចូលរួមនៅក្នុងការបង្កើត និង អនុវត្តនូវបទបញ្ញត្តិទាំងនេះ។ ខ្ញុំទទួលបាននូវ ការយល់ដឹងកាន់តែទូលំទូលាយថែមទៀតពីសារៈសំខាន់នៃការចូលរួមនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ (CBNRM)។

## សមត្ថភាព និង សេចក្តីជឿជាក់

ខ្ញុំក៏បានរៀនផងដែរពីវិធីសាស្ត្រនៃការវិភាគអ្នកជាប់ពាក់ពន្ធ័ និង ការគ្រប់គ្រងជំលោះរវាង និង ក្នុងចំណោមអ្នកប្រើប្រាស់ធន-ធាន។ ជំលោះអាចកើតមានឡើងរវាងសហគមន៍ និង អ្នកមានអំណាចមកពីខាងក្រៅ ដូចជា អ្នកធ្វើជំនួញធំៗ និង ក្នុងចំណោមប្រជាជនក្នុងសហគមន៍។ សមត្ថភាពរបស់ខ្ញុំក្នុងការវិភាគពីបញ្ហាជំលោះមានការប្រសើរឡើង ហើយ ការជឿជាក់របស់ខ្ញុំក្នុងការធ្វើកិច្ចការនេះក៏មានការកើនឡើងដែរ។



*Ka Uper (វីនតាពណ៌ខ្មៅ នៅជួរទីមួយរាប់ពីឆ្វេង) ជាមួយអ្នកនេសាទ និង អ្នកចូលរួមទស្សនៈកិច្ចសិក្សារបស់ SPARK នៅតំបន់ព្រៃកោងកាងភាគខាងជើងប្រទេសថៃ*

អង្គការរបស់យើងឥឡូវនេះកំពុងគ្រប់គ្រងទី-ជំរកត្រីបីកន្លែងដែលកន្លែងនិមួយៗមានទំហំ ២០០ x ១០០ ម ដែលផ្តល់មូលនិធិដោយរដ្ឋាភិបាល។ យើងក៏កំពុងដាំព្រៃកោងកាងឡើងវិញចំនួន ៤៥ ហ.ត ដែលឧបត្ថម្ភដោយ Oxfarm GB និង PACAP ជាភ្នាក់ងារផ្តល់មូលនិធិរបស់អូស្ត្រាលី។ សមាជិករបស់យើងម្នាក់គឺជាប្រធាននៃក្រុមប្រឹក្សាគ្រប់គ្រងធន-ធានវារីជាត និង ជលផល ដែលធ្វើការផ្តល់អនុសាសន៏លើគោលនយោបាយទាក់ទងនឹងការគ្រប់គ្រងធនធានវារីជាតដល់រដ្ឋាភិបាល។ យើងសកម្មក្នុងយុទ្ធនាការប្រឆាំងនឹងការរនេសាទខុសច្បាប់ដោយមានការជួយជ្រោមជ្រែងពីបណ្តាញសារពតិមានជាតិ។ យើងបានជំរុញឱ្យអាជ្ញាធរកុំអនុម័តលើដំណើរការសាងសង់រោងចក្រស៊ីម៉ង់ត៍ដែលបំផ្លិចបំផ្លាញព្រៃកោងកាងរបស់យើង និង បំពុលដល់កន្លែងនេសាទរបស់យើង។ យើងក៏បានចូលរួមក្នុងការការពារផ្កាថ្មដែលនៅសេសសល់នៅឆក Pagapas ដោយមានការជួយឧបត្ថម្ភពីរដ្ឋាភិបាល។ ថ្មីៗនេះខ្ញុំត្រូវបានគេជ្រើស រើសជាសមាជិកក្រុមប្រឹក្សាជាតិនៃ គណៈកម្មការកាត់បន្ថយភាពក្រីក្រជាតិ។

ពីមុនគេគិតថាការគ្រប់គ្រងធនធានសមុទ្រគួរតែទុកឱ្យអ្នកជំនាញការជលផលជាអ្នកធ្វើ យើងក៏ចង់បញ្ជាក់ដែរថាអ្នកប្រើប្រាស់ធនធានក៏អាចជាអ្នកគ្រប់គ្រងធនធានផងដែរ។

លោក Ka Uper គឺជានាយកនៃ SAMMACA។ លោក Jocel Pangilinanគឺជាអ្នកជំនួយការឱ្យកម្មវិធី SPARK និង លោក Ronet Santos គឺជាអ្នកសំរបសំរួលកម្មវិធី SPARK។ លោកអ្នកអាចទាក់ទងលោក Ka Uper តាមរយៈអង្គការ CERD, 102 E R&L Mendoza Building, Kamuning Road, Quezon City, Philippines, < cerd@skyinet.net > . Jocel និង Ronet អាចទាក់ទងតាមរយៈ < spark@qinet.net >។

ការផ្លាស់ប្តូរសំខាន់គឺជាប្រពន្ធ័ត្រួតពិនិត្យដោយមានការចូលរួមដែលបានប្រើដោយអង្គការ VSO។ វាគឺជាវិធីសាស្រ្តថ្មីមួយដើម្បីធ្វើការត្រួតពិនិត្យគំរោង ដែលបានសហការគ្នាអភិវឌ្ឍន៍ជាមួយគណៈកម្មការយេស៊ូគ្រីស្តដើម្បីអភិវឌ្ឍន៍នៅប្រទេសបង់ក្លាដែស (CCDB)ក្នុងឆ្នាំ ១៩៩៤។ វាត្រូវបានគេបង្កើតឡើងដើម្បីអភិវឌ្ឍន៍គំនិតមួយពីការរៀនសូត្រនៅក្នុងអង្គការ។ ការបង្កើតនេះគឺមានគោលបំណងលុបចោលនូវការប្រើ "សន្ទស្សន៍ " ដែលជាចំណុចសំខាន់នៃវិធីសាស្រ្តត្រួតពិនិត្យ។ ការផ្តោតជាសំខាន់របស់ប្រពន្ធ័គឺលើការរកនូវការផ្លាស់ប្តូរសំខាន់ជាការសំគាល់ និង បកស្រាយដោយអ្នកចូលរួមទាំងអស់។ វាអាស្រ័យទៅលើការប្រើ-ប្រាស់ពតិមានមានលក្ខណៈជាគុណភាព មិនមែនជាបរិមាណទេ។

# ការផ្លាស់ប្តូរសំខាន់ដោយក្រុមសិក្សាពីការចិញ្ចឹមជីវិតខេត្តរបស់ប្រទេសកម្ពុជា

Bun Hay Cheng, Tan Someth Bunwhat, Mey Chanthou and Bun Puthy

## និរន្តរភាព ការសិក្សាពីការចិញ្ចឹមជីវិត ការកសាងសមត្ថភាព និង ការផ្លាស់ប្តូរសំខាន់

ដែននេសាទរបស់ប្រទេសកម្ពុជាកំពុងស្ថិតនៅក្រោមការកែទំរង់ដែលក្នុងនោះឡូត៍នេសាទជាច្រើនស្ថិតនៅក្រោមការទទួលខុសត្រូវរបស់សហគមន៏។ សហគមន៏នេសាទជាច្រើនជួបប្រទះបញ្ហាដោយពួកគេមិនយល់ពីរបៀបប្រើប្រាស់ធនធានវារិជាតឱ្យមាននិរន្តរភាព ឬក៏ពីការការពារកុំឱ្យមានការបំផ្លិចបំផ្លាញរបស់ពួកគេពីមួយថ្ងៃទៅមួយថ្ងៃ។ រដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមបង្កើតគណៈកម្មការសហគ្រប់គ្រងដើម្បីការពារធនធានធម្មជាតិនៅក្នុងសហគមន៏។ ការសិក្សាពីការចិញ្ចឹមជីវិតដោយនិរន្តរភាពបានធ្វើនៅភូមិដើម្បីស្វែងរកនូវបញ្ហា និង ដំណោះស្រាយ ដូច្នេះអ្នកភូមិអាចបង្កើតនូវយុទ្ធសាស្ត្រសំរាប់ការចិញ្ចឹមជីវិតរបស់ពួកគេជៀសវាងនូវបញ្ហា និង អភិរក្សធនធានធម្មជាតិ។

ការកសាងសមត្ថភាពដើម្បីធ្វើការសិក្សាពីការចិញ្ចឹមជីវិតដោយនិរន្តរភាពត្រូវបានធ្វើឡើងដោយកម្មវិធី SCALE ” ក្រុមគ្រូបំពាក់បំប៉ន ”ជាមួយនឹងក្រុមការចិញ្ចឹមជីវិតដោយនិរន្តភាពខេត្ត កណ្តាល កំពង់ឆ្នាំង និង ក្រចេះ។ អ្នកភូមិមានឱកាសពិភាក្សា និង ចាប់ផ្តើមដោះស្រាយនូវបញ្ហាបច្ចុប្បន្ន និង អនាគតដែលទាក់ទងនឹងបញ្ហាបរិស្ថាន ធនធានវារីជាត និង សត្វព្រៃ។ កម្មវិធី SCALE ក៏បានពិនិត្យមើលលើដំណើរការកសាងសមត្ថភាព ដោយមានគោលបំណងធ្វើអត្តសញ្ញាណ និង រៀបរាប់ពីការផ្លាស់ប្តូរសំខាន់ដូចជា ចំណេះដឹង អាកប្បកិរិយា និង ការអនុវត្តន៏ផ្ទាល់ ក្នុងចំណោមសមាជិកនៃក្រុមសិក្សាក្នុងខេត្តទាំង៣ ដែលមួយក្រុមៗមានគ្នា៦នាក់មកពីការិយាល័យជលផលខេត្ត៤នាក់ និង មន្ទីរកិច្ចការនារីខេត្ត២នាក់។

## វិធីសាស្ត្រៈ ការត្រួតពិនិត្យ ការអង្កេត សំណួរ និង របាយការណ៏

ក្នុងពេលធ្វើការសិក្សាពីការចិញ្ចឹមជីវិតដោយនិរន្តរភាព កម្មវិធី SCALE បានពិនិត្យមើលលើការងាររបស់ក្រុមនិមួយៗដើម្បីស្វែងយល់ពីចំណេះដឹង អាកប្បកិរិយា ការអនុវត្តន៏របស់ពួកគេ។ គ្រូបំពាក់បំប៉នតាមដានរាល់សកម្មភាពធ្វើការវាយតំលៃដោយមានការចូលរួម (PRA) នៅតាមភូមិនិមួយៗ ដូចជាការជ្រើសរើសភូមិ វិធីសាស្ត្រសំរបសំរួល ការប្រើប្រាស់នូវ Toolទាំងឡាយរបស់ PRA ដើម្បីប្រមូលនូវពតិមាន និង វិភាគនូវបញ្ហា ការប្រើប្រាស់កុំព្យូទ័រ និង ការសរសេររបាយការណ៏។

គ្រូបំពាក់បំប៉នរបស់កម្មវិធី SCALEបានកត់ត្រានូវការអង្កេតរបស់ខ្លួនពីចំណេះដឹង អាកប្បកិរិយា និង ការអនុវត្តន៏របស់សមាជិកក្រុមសិក្សា ទាំងក្នុងកំឡុងពេលបំពាក់បំប៉ន និង ការអនុវត្តន៏នៅតាមភូមិ។ ជាពិសេស គ្រូបំពាក់បំប៉នបានអង្កេតទៅលើចរិតលក្ខណៈនៃមនុស្សនៅក្នុងក្រុមនិមួយៗ អ្នកដែលធ្វើការជាមួយគ្នានិងពីរបៀប ដោយផ្តោតជាសំខាន់ទៅលើស្ត្រី។

សមាជិកនៃក្រុមសិក្សាខេត្តទាំងអស់ត្រូវបំពេញសំនួរដើម្បីចង់ដឹងពីចំណេះដឹងពី PRA មុនពេលធ្វើការបំពាក់បំប៉ន។ ក្រោយការបំពាក់បំប៉ន និង ក្រោយពីការធ្វើ PRA នៅភូមិទីពីររួចមកសមាជិកទាំងអស់ត្រូវបំពេញសំនួរម្តងទៀត។ របាយការណ៏ពីការផ្លាស់ប្តូរសំខាន់ត្រូវបានសរសេរដោយសមាជិកក្រុមសិក្សានិមួយៗ ដោយអធិប្បាយពីតើគេមានការផ្លាស់ប្តូរអ្វីខ្លះ ហើយនៅពេលណា? ។ ការសរសេរនេះត្រូវបានរៀបចំឡើងតាមរយៈការពិភាក្សាជាក្រុម។

**លទ្ធផល**

ដោយមិនអាចដាក់បញ្ចូលនូវលទ្ធផលនៃការសិក្សា ឬក៏បញ្ជីរសំនួរនៅក្នុងអត្ថបទនេះ ការសន្និដ្ឋានពីការផ្លាស់ប្តូរសំខាន់មានដូចតទៅ:

- ក្រុមនិមួយៗបានចាប់ផ្តើមយល់ពីការប្រើប្រាស់នូវ Tool ទាំងឡាយរបស់ PRA ដើម្បីប្រមូលពតិមានពីភូមិ
- ក្រុមទាំងអស់អាចធ្វើ PRA ដោយខ្លួនឯងនៅភូមិទីពីរ
- ជាទូទៅ ក្រុមទាំងអស់បានធ្វើការជាក្រុមបានល្អ។ ពួកគេបានយល់ពីរបៀបធ្វើ PRA ដោយមានការទទួលខុសត្រូវ និងប្តេជ្ញាខ្ពស់
- បុរស និង ស្ត្រី មានការសហការធ្វើការបានល្អ
- ពួកគេត្រូវការនូវបទពិសោធបន្ថែមទៀតពី ការធ្វើ PRA ការវិភាគបញ្ហា ការប្រើប្រាស់កុំព្យូទ័រ និង ការសរសេររបាយការណ៏។

**រឿងរ៉ាវនៃការផ្លាស់ប្តូរសំខាន់ផ្ទាល់ខ្លួន**

នៅខែ កញ្ញា ២០០២ កិច្ចប្រជុំពីការចិញ្ចឹមជីវិត CFDO-SCALE-STREAM បានប្រព្រឹត្តទៅនៅនាយកដ្ឋានជលផលនាទីក្រុងភ្នំពេញ ដើម្បីរាយការណ៏ និង ទទួលយកនូវការឆ្លើយតបពីលទ្ធផលនៃការសិក្សាពីការចិញ្ចឹមជីវិតនៅក្នុងខេត្តទាំង៣។ ការសន្និដ្ឋានដែលផ្តោតនៅក្នុងកិច្ចប្រជុំនោះគឺ អ្នកស្ម័គ្រចិត្តម្នាក់មកពីក្រុមនិមួយៗបានរៀបរាប់ពីរឿងរ៉ាវនៃការផ្លាស់ប្តូរសំខាន់ផ្ទាល់ខ្លួន។

*ពីខេត្តកណ្តាល*

ខ្ញុំឈ្មោះ ប៊ុន ពុទ្ធី ធ្វើការនៅមន្ទីរកិច្ចការនារីខេត្តកណ្តាល។ មុនពេលធ្វើការជាមួយ STREAM ខ្ញុំអត់បានដឹងពីអ្វីទៅថា PRA។ ខ្ញុំតែងតែនិយាយច្រើន និង បង្រៀនពួកគេនៅពេលខ្ញុំធ្វើការនៅតាមភូមិ ហើយអាកប្បកិរិយារបស់ខ្ញុំគឺជាអ្នកដឹកនាំចង្អុលនូវរាល់ការងារ។ ក្នុងរយៈពេល៣ខែ ខ្ញុំបានយល់ច្បាស់ពី PRA Tools និងការអនុវត្តន៏ និងពីរបៀបប្រមូលពតិមានពីអ្នកភូមិ។ ខ្ញុំបានយល់ពីរបៀបធ្វើការនៅជាក្រុម មានទំនាក់ទំនងល្អជាមួយសមាជិកនៃក្រុម និង ចាត់ចែងភារកិច្ចបានល្អសំរាប់ក្រុម។ ជាងនេះទៅទៀត ខ្ញុំតែងតែយកចិត្តទុកដាក់លើការវាយតំលៃខ្លួនឯងនៅក្នុងក្រុមបន្ទាប់ពីបញ្ចប់ PRA Tool និមួយៗ។ អ្វីដែលសំខាន់សំរាប់ខ្ញុំគឺខ្ញុំអាចស្នាក់នៅជាមួយអ្នកភូមិ និង ស្វែងយល់បានច្បាស់ពីគំរិតជីវភាពរស់នៅពិតប្រាកដរបស់អ្នកភូមិ និង ខ្ញុំបានវិភាគរាល់ពតិមានដែលមាននៅក្នុងភូមិ។ ជាពិសេស ខ្ញុំរីករាយ និង ចង់ធ្វើ PRAបន្តទៅទៀតនៅតាមភូមិ ពីព្រោះខ្ញុំចាប់អារម្មណ៏ពីការរកឃើញនូវបញ្ហា និង ដំណោះស្រាយសំរាប់កសិករក្រីក្រនៅតាមភូមិ។ ដូច្នេះក្នុងរយៈពេលនេះ ខ្ញុំទទួលបាននូវបទពិសោធកាន់តែច្រើន និង ការងាររបស់ខ្ញុំកាន់តែប្រសើរឡើងទាំងការងារនៅការិយាល័យ និង នៅមូលដ្ឋាន។

*ពីខេត្តកំពង់ឆ្នាំង*

ខ្ញុំឈ្មោះ ម៉ី ចាន់ធូ ធ្វើការនៅមន្ទីរកសិកម្មខេត្តកំពង់ឆ្នាំង។ ខ្ញុំមិនដែលបានដឹងអ្វីទៅជា PRA Tool កម្មវិធីរបស់កុំព្យូទ័រ និង ពីរបៀបសរសេររបាយការណ៏។ អត្តចរិតរបស់ខ្ញុំគឺខ្ញុំមិនសូវចូលចិត្តនិយាយច្រើន ហើយមិនដែលធ្វើការនៅតាមភូមិ។ ប៉ុន្តែនៅពេលខ្ញុំធ្វើការជាមួយ STREAM ក្នុងរយៈពេល៣ខែ ខ្ញុំបានយល់ច្បាស់ពី Tools របស់ PRA។ ខ្ញុំអាចធ្វើការដោយផ្ទាល់

ជាមួយកសិករ។ ខ្ញុំអាចប្រមូលពតិមាន និង សរសេររបាយការណ៏។ ខ្ញុំបានចេះកម្មវិធីរបស់កុំព្យូទ័រកាន់តែច្រើនថែមទៀតដូចជា FreeHand, Arcview, Word និង Excel។ ខ្ញុំបានស្តាប់ និង រៀនយ៉ាងច្រើនពីអ្នកភូមិ ពីព្រោះជាការសំខាន់ណាស់សំរាប់ខ្ញុំ ត្រូវតែសកម្ម។ ម្យ៉ាងវិញទៀត ខ្ញុំបានស្នាក់នៅ និងធ្វើការជាមួយអ្នកភូមិដែលមានស្ថានភាពរស់នៅផ្សេងៗគ្នា។ ជាទីបញ្ចប់ ជីវិតរបស់ខ្ញុំមានការផ្លាស់ប្តូរជាសំខាន់លើ ចំណេះដឹង អាកប្បកិរិយា និង ការអនុវត្តន៏។

*ពីខេត្តក្រចេះ*

ខ្ញុំឈ្មោះ តាន់ សុមេតប៊ុនវឌ្ឍ។ ខ្ញុំធ្វើការនៅការិយាល័យជលផលខេត្តក្រចេះ។ មុនពេលធ្វើការជាមួយ STREAMខ្ញុំអត់ដឹងពី PRA Tool ពីរបៀបធ្វើផែនកាសកម្មភាព និង ពីរបៀបវិភាគពតិមាន និង សរសេររបាយការណ៏ទេ។ តែក្នុងរយៈពេល៣ ខែ ខ្ញុំបានដឹងពីរបៀបធ្វើផែនការ និង ធ្វើការជាក្រុម ជាពិសេសជាមួយស្ត្រី។ សមត្ថភាពរបស់ខ្ញុំក្នុងការប្រើប្រាស់កុំព្យូទ័រត្រូវបានលើកកំពស់។ អាកប្បកិរិយារបស់ខ្ញុំមានការផ្លាស់ប្តូរពីគំនិតបញ្ជាទៅជាការទទួលយកនូវគំនិត និង បញ្ហាពីអ្នកភូមិ និង អាចស្នាក់នៅជាមួយអ្នកភូមិ។ ខ្ញុំអាចទំនាក់ទំនងបានយ៉ាងល្អជាមួយអ្នកភូមិ និង អាជ្ញាធរមូលដ្ឋាន និង ខ្ញុំបានរៀនយ៉ាងច្រើនពីអ្នកភូមិ។ សមត្ថភាពរបស់ខ្ញុំមានការកើនឡើង។

លោក ប៊ុន ហាក់នេងគឺជាអ្នកគ្រប់គ្រងនៅស្ថានីយ៏ស្រាវជ្រាវ និង ផលិតកូនត្រីនៃកម្មវិធី SCALE ហើយអាចទាក់ទងតាមរយៈ < 012809091@mobitel.com.kh >។ លោក តាន់ សុមេតប៊ុនវឌ្ឍគឺជាមន្ត្រីធ្វើនៅការិយាល័យជលផលខេត្តក្រចេះ។ លោកស្រី ម៉ី ចាន់ធូ គឺជាមន្ត្រីធ្វើការនៅមន្ទីរកសិកម្មខេត្តកំពង់ឆ្នាំង។ លោកស្រី ប៊ុន ពុទ្ធី គឺជានាយិការងនៃមន្ទីរកិច្ចការនារីខេត្តកណ្តាល។ លោកអ្នកអាចទាក់ទងតាមរយៈ < cfdo@camnet.com.kh >។

## ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ(CFDO ) ក្នុងរយៈពេលមួយឆ្នាំ

### ការធ្វើដំណើររបស់ CFDO....

គំនិតដ៏ឆ្លាតវៃមួយគឺការអាចធ្វើដំណើរដ៏វែងឆ្ងាយបានចាប់ផ្ដើមពីការឈានមួយជំហានក្នុងទិសដៅដែលត្រឹមត្រូវ។ បន្ទាប់ពីមានជំលោះកាន់តែខ្លាំងឡើងរវាងអ្នកនេសាទគ្រួសារ និង អ្នកនេសាទឧស្សាហកម្មនៅបឹងទន្លេសាប នាយកមន្ត្រីបានប្រកាសនៅខែតុលា ឆ្នាំ ២000 ប្រហែលជាងពាក់កណ្ដាលនៃឡូត៍នេសាទត្រូវបានប្រគល់ជូនដល់ប្រជាជន។ ផ្ទៃទាំងនេះ (ប្រហែលកន្លះលានហិចតា) គឺត្រូវបានគ្រប់គ្រងដោយសហគមន៍នេសាទខ្លួនឯង ដោយមានការណែនាំ និង ជួយគាំទ្រពីរដ្ឋាភិបាល។ ជាជំហានមួយនៅក្នុងដំណើរការនេះ ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ (CFDO) នៃនាយកដ្ឋានជលផលត្រូវបានបង្កើតឡើងកាលពីឆ្នាំទៅដើម្បីជួយក្នុងដំណើរការកែទំរង់នេះ។



*ការកែទំរង់វិស័យជលផល និង ការគ្រប់គ្រងតាមបែបសហគមន៍គឺបានផ្ដល់នូវសំលេងដល់អ្នកប្រើប្រាស់ធនធានវារិជាតិទាំងអស់។ នេះគឺជាការរង់ចាំរបស់សហគមន៍ដើម្បីដឹងពីលទ្ធផលនៃការជ្រើសរើសគណៈកម្មការសហគម*

CFDO គឺទទួលខុសត្រូវក្នុងការអនុវត្តន៍ សំរបសំរួល និង ជួយដល់សហគមន៍នេសាទ។ ឥឡូវនេះសហគមន៍នេសាទចំនួនជាង ២៤0ត្រូវបានបង្កើតទាំងនៅតំបន់ទឹកសាប និង សមុទ្រ ភាគច្រើនបង្កើតចាប់តាំងពីការប្រកាសឱ្យមានការកែទំរង់។ ប្រធាននាយកដ្ឋានជលផល លោក ណៅ ធួក មានប្រសាសថា " គំនិតនៃការគ្រប់គ្រងសហគមន៍នេសាទគឺជារឿងមួយថ្មីសំរាប់ប្រទេសកម្ពុជា។ ប៉ុន្តែវាត្រូវបានគេគិតថាជាប្រពន្ធ័គ្រប់គ្រងមួយដើម្បីគ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាពដែលមានលក្ខណៈប្រហាក់ប្រហែលទៅនឹងប្រពន្ធ័គ្រប់គ្រងដែលបានសាកល្បងជាង១0ឆ្នាំនៅប្រទេសជាច្រើនដូចជានៅប្រទេសហ្វីលីពីន។ យើងអាចរៀនពីបទពិសោធទាំងនេះដូចជាក្មេងដែលរៀនដើរដូច្នេះដែរ "។

នៅឆ្នាំដំបូង CFDO មានបុគ្គលិកកើនឡើងចំនួន ២៥ នាក់។ ពួកគេមានជំនាញខុសៗគ្នា ដែលភាគច្រើនធ្វើការនៅតាមមូលដ្ឋានជាមួយនាយកដ្ឋានជលផល។ ប៉ុន្តែមានបុគ្គលិក ២-៣ នាក់ដែលធ្លាប់មានបទពិសោធទាក់ទងនឹងការគ្រប់គ្រងតាមបែបសហគមន៍នេះ។ វគ្គបំពាក់បំប៉នបានចាប់ផ្ដើមដើម្បីរៀបចំ CFDO ប្រឈមមុខនឹងការងារអនុវត្ត និង សំរបសំរួលការគ្រប់គ្រងធនធានជលផលតាមបែបសហគមន៍។ CFDO ក៏បានចាប់ផ្ដើមធ្វើគំរោងស្រាវជ្រាវជាច្រើនដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីបញ្ហាដែលប៉ះពាល់ដល់ការអនុវត្តន៍សហគ្រប់គ្រងនៅក្នុងសហគមន៍នេសាទក្រីក្រ។

### គំរោង STREAM និង ការសិក្សាពីការចិញ្ចឹមជីវិត

CFDO គឺជាស្ថាប័នដំបូងបង្អស់ដែលធ្វើការជាមួយគំរោង STREAM ថ្នាក់តំបន់។ ក្នុង CFDO គំរោង STREAM បានផ្ដល់ជាប្រាក់ខែសំរាប់អ្នកគ្រប់គ្រងម្នាក់ដើម្បីទទួលខុសត្រូវលើការអភិវឌ្ឍន៍មណ្ឌលទំនាក់ទំនងជាតិ និង លើកកំពស់ទំនាក់ទំនងជាមួយអ្នកជាប់ពាក់ពន្ធ័ថ្នាក់តំបន់ ដើម្បីចែករំលែកចំណេះដឹង និង ផ្លាស់ប្ដូរនូវពត៌មាន។ អ្នកស្ម័គ្រម្នាក់បានធ្វើការនៅ CFDO ដើម្បីផ្ដល់នូវការប្រឹក្សាលើការគ្រប់គ្រង និង បញ្ហាស្ថាប័ន។

ដោយមានការសហការជាមួយកម្មវិធី SCALE, CFDO បានធ្វើការសិក្សាពីការចិញ្ចឹមជីវិតដែលពឹងផ្អែកលើធនធានជលផលនៅក្នុងខេត្ត កណ្តាល កំពង់ឆ្នាំង និង ក្រចេះ ដោយមានការជួយឧបត្ថម្ភពី STREAM ។ ទីកន្លែងសិក្សារួមមានតំបន់បឹងទន្លេសាប ទន្លេមេគង្គ និង តំបន់វាលស្រែដែលលិចទឹកនៅរដូវវស្សា។ ដើម្បីស្វែងយល់ពីជីវភាពរស់នៅរបស់អ្នកនេសាទកាន់តែច្បាស់ វិធីសាស្ត្រវាយតំលៃដោយមានការចូលរួមត្រូវបានគេយកទៅប្រើប្រាស់ដើម្បីប្រមូលពតិមានដោយផ្ទាល់ពីអ្នកប្រើប្រាស់ធនធាន។ ការសិក្សាបានផ្តោតជាសំខាន់ទៅលើការកសាងសមត្ថភាពរបស់មន្ត្រី CFDO ការិយាល័យជលផលខេត្ត និង មន្ទីរកិច្ចការនារីខេត្ត លើការងារស្រាវជ្រាវ និង សំរបសំរួល។ របាយការណ៍ស្តីពី សហគមន៍នេសាទនឹងផ្តល់ជូនដល់អ្នកជាប់ពាក់ព័ន្ធសំខាន់ៗ និង អាចយកទៅប្រើប្រាស់ដើម្បីអភិវឌ្ឍន៍ទៅជាគំរោងក្នុងសហគមន៍នេសាទ។ តាមរយៈការសិក្សា ដោយមានការចូលរួមរបស់អ្នកភូមិអាចឱ្យយើងធ្វើអាទិភាពពីបញ្ហាដែលជះឥទ្ធិពលលើការចិញ្ចឹមជីវិតរបស់ពួកគេ និង ការស្វែងរកដំណោះស្រាយ។

## ការសិក្សាពីការចិញ្ចឹមជីវិតរបស់គំរោង ICLARM



*CFDO ជួយធានាដល់សិទ្ធរបស់អ្នកនេសាទក្រីក្រតាមរយៈសហគ្រប់គ្រង*

ជាមួយនឹងទីភ្នាក់ងាររដ្ឋាភិបាលប្រទេសបង់ក្លាដែស ឡាវ និង វៀតណាម CFDO បានចូលនៅក្នុងគំរោងដែលឧបត្ថម្ភដោយ ICLARM ដែលពិនិត្យលើការចិញ្ចឹមជីវិតដោយពឹងផ្អែកទៅលើជលផលទឹកសាប។ ការសិក្សាមានគោលបំណងរកឱ្យឃើញនូវការពឹងផ្អែករបស់អ្នកក្រីក្រលើធនធានវារីជាត លក្ខណៈនៃភាពក្រីក្រ និង វាយតំលៃពីភាពងាយរងគ្រោះនៃប្រជាជនក្រីក្រដោយសារតែការគ្រប់គ្រងមិនបានត្រឹមត្រូវនៃធនធានវារីជាត។ គេប្រមាណថា ពតិមានដែលប្រមូលបានពីប្រទេសទាំង៤ នឹងជួយដល់អ្នកគ្រប់គ្រងធនធានវារីជាត និង អ្នកវិទ្យាសាស្ត្រទាំងអស់ឱ្យបានយល់ពីទំនាក់ទំនងរវាងប្រជាជនក្រីក្រ និង ធនធាន។ ការផ្តោតជាពិសេសគឺលើអាទិភាពនៃការស្រាវជ្រាវនាពេលអនាគត និង "ចំណុចចាប់ផ្តើម" នៃការកាត់បន្ថយភាពក្រីក្រ។

## វគ្គបំពាក់បំប៉នរបស់ CFDO

ដោយមានការជួយជ្រោមជ្រែងពីអ្នកស្ម័គ្រចិត្ត CFDO បានជាប់រវល់ក្នុងការរៀបចំ និង សំរបសំរួលកម្មវិធីបំពាក់បំប៉នរបស់ខ្លួនដោយមានការជួយឧបត្ថម្ភពីអង្គការក្រៅរដ្ឋាភិបាល និង បុគ្គលដែលជាប់ទាក់ទងនឹងការគ្រប់គ្រងសហគមន៍នេសាទនៅកម្ពុជា។ បុគ្គលិកទាំងអស់បានចូលរួមធ្វើទស្សនៈកិច្ចសិក្សាទៅសហគមន៍នេសាទនៅតំបន់ទឹកសាប និង សមុទ្រ។ ពួកគេចូលរួមនៅក្នុងសកម្មភាពដែលផ្តោតលើគំនិតនៃសហគ្រប់គ្រង ដែលរួមមានៈ បញ្ហាព្រំប្រទល់ ជំលោះ ការអភិវឌ្ឍន៍ និង បញ្ហានិរន្តរភាព និង គោលនយោបាយ។ លោក ថាយសុមុនី ប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ (CFDO) បានមានប្រសាសថា "ការបំពាក់បំប៉ននឹងផ្តល់ឱ្យបុគ្គលិករបស់យើងនូវឧបករណ៍ដែលគេត្រូវការដើម្បីអនុវត្តសហគ្រប់គ្រងវិស័យជលផល និង ធ្វើការជូនសហគមន៍នេសាទកាន់តែប្រសើរ"។

CFDO សូមថ្លែងអំណរគុណចំពោះជំនួយថវិការ និង សប្បុរសធមិ៌នៃសមភាគីទាំងនេះៈ American Friends Service Committee, Cambodian Family Development Service, CBNRM និង WWF, FAO Siem Reap, IDRC, MRC Capture Fisheries Project, MRC Reservoir Project, Oxfam America, Oxfam GB និង SADP ។ ជាងនេះ

ទៅទៀត CFDO យល់ឃើញថាឱកាសនេះគឺជាការលើកកំពស់នូវទំនាក់ទំនង និង សំរបសំរួលក្នុងចំណោមអ្នកជាប់ពាក់ពន្ធ័សហគមន៍នេសាទទាំងអស់។

**នៅពេលអនាគត....**

CFDOសង្ឃឹមថានឹងលើកកំពស់នូវទំនាក់ទំនងជាមួយអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការក្នុងផ្នែកការគ្រប់គ្រងធនធានជលផលតាមបែបសហគមន៍ និង វិស័យដែលទាក់ទង។ លោក ថាយ សុមុនីបានឱ្យយោបល់ថា " អង្គការក្រៅរដ្ឋាភិបាលបានដើរតួរយ៉ាងសំខាន់ក្នុងការបង្កើត និង ជួយដល់សហគមន៍នេសាទនៅកម្ពុជា..... CFDO ចង់សហការ និង សំរបសំរួលឱ្យបានច្រើនជាមួយអង្គ-ការ និង ធ្វើការជាមួយគ្នាលើគំរោងរួមគ្នានៅពេលអនាគត "។ កិច្ចប្រជុំរវាងអ្នកជាប់ពាក់ពន្ធ័ត្រូវបានប្រារព្ធធ្វើរួចមកហើយជាមួយអង្គការក្រៅរដ្ឋាភិបាលដែលពាក់ពន្ធ័។ CFDOនឹងព្យាយាមដើម្បីធានាឱ្យអ្នកជាប់ពាក់ពន្ធ័ទាំងអស់ស្ថិតនៅក្នុងរង្វង់មួយដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ហើយយើងជឿជាក់ថា ទំនាក់ទំនងនេះនឹងបង្កើតជាមូលដ្ឋានមួយដើម្បីគ្រប់គ្រងធនធានជលផលតាមបែបសហគមន៍ឱ្យមានប្រសិទ្ធភាព សមភាព និង មានតម្លាភាពក្នុងរយៈពេលយូរ។

លោក Matt Fox គឺជាយុវអគ្គរាជទូតនៃអូស្ត្រាលីដើម្បីអភិវឌ្ឍន៍ (AYAD) ដែលធ្វើការនៅ CFDO ភ្នំពេញ។
លោកអ្នកអាចទាក់ទងតាមរយៈ < cfdo@camnet.com.kh >

## ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ(CFDO) បើកការរកស៊ី!

Louise Mackeson-Sandbach

នៅពេលចុងបញ្ចប់នៃការងាររបស់អ្នកស្ម័គ្រចិត្ត របាយការណ៍ និង ការសើរើលើលទ្ធផលការងារត្រូវបានបំពេញដោយអ្នកស្ម័គ្រចិត្ត និយោជករបស់នាង និង អ្នកជិតស្និទ្ធ។ ដំណើរការនេះក៏រួមបញ្ចូលនូវការសរសេរ " រឿងរ៉ាវផ្លាស់ប្តូរសំខាន់ " ដែលត្រូវបានចែករំលែកជាមួយសហការីដើម្បីពិភាក្សា កែសំរួល និង ជ្រើសរើសដើម្បីធ្វើជាផ្នែកមួយនៃរបាយការណ៍លទ្ធផលការងារ ហើយបន្ទាប់មកត្រូវដាក់នូវចំណងជើង " ដែលជាចំណងជើងដែលបានដាក់នេះ "។ រូបភាពពីរនេះ "ពីមុន " និង " បន្ទាប់មក " ត្រូវបានដាក់ជូនជាផ្នែកមួយនៃរបាយការណ៍ ហើយដែលបានដកស្រង់ចេញពី " រឿងរ៉ាវនៃការផ្លាស់ប្តូរសំខាន់ " ដែលសរសេរដោយកញ្ញា Louise ។

**រូបភាពពីមុន**



ក្នុងកំឡុងពេលនៃការធ្វើការងាររបស់អ្នកស្ម័គ្រចិត្ត ការផ្លាស់ប្តូរបានកើតមានលើ បរិយាកាសនៃការិយាល័យ កំលាំងចិត្ត និង ការជឿជាក់របស់បុគ្គលិក។

**បន្ទាប់មក**



ការិយាល័យមានបរិស្ថានការងារដ៏ល្អ... មានទំនាក់ទំនងល្អរវាងបុគ្គលិក ហើយជាកន្លែងមួយដែលគួរឱ្យចង់ធ្វើការ ។ ការកើនឡើងនូវសកម្មភាព និង វត្តមានរបស់បុគ្គលិក បានបង្កើតបរិយាកាសមួយល្អសំរាប់ការិយាល័យ ។ បុគ្គលិកទាំងអស់ចាប់ផ្តើមធ្វើការជាមួយគ្នាជាក្រុមបានល្អ ទាំងបុរស និង ស្ត្រី ។

កញ្ញា Louise Mackeson-Sandbach បានធ្វើការជាទីប្រឹក្សាគ្រប់គ្រងរបស់ CFDO នៃនាយកដ្ឋានជលផល នៅក្នុងទីក្រុងភ្នំពេញ ពីខែ កុម្ភៈ ដល់ខែ វិច្ឆិកា ២០០២ ។ កញ្ញា Louise ឥឡូវនេះបានត្រលប់ទៅប្រទេសអង់គ្លេសវិញ
លោកអ្នកអាចទាក់ទងតាមរយៈ < louise_mackeson@hotmail.com > ។

# ការជាប់ពាក់ព័ន្ធនៃស្ថាប័ន និង អ្នកជាប់ពាក់ព័ន្ធក្នុងការគ្រប់គ្រង និង អភិវឌ្ឍន៍វិស័យវារីវប្បកម្ម

M Krishnan និង Pratap S Birthal

## សេចក្តីត្រូវការនៃវារីវប្បកម្មសមុទ្រ

ការវាយតំលៃនៅពេលបញ្ចប់គំរោងនៅប្រទេសឥណ្ឌានាពេលថ្មីៗនេះ ក្រុមរបស់យើងបានដឹកនាំការអង្កេតពីការធ្វើវារីវប្បកម្ម នៅស្រុក Nellore នៃរដ្ឋ Andhra Pradesh និង ស្រុក Cuddalore នៃរដ្ឋ Tamil Nadu ។ ជាងនេះទៅទៀត នៅពេលបញ្ចប់គំរោង ក្រុមបានរកឃើញនូវសេចក្តីត្រូវការដែលតំរូវឱ្យមានការយកចិត្តទុកដាក់ដើម្បីធ្វើឱ្យវារីវប្បកម្មសមុទ្រក្លាយទៅជាសកម្មភាពសេដ្ឋកិច្ចមួយសំខាន់ ។ សេចក្តីត្រូវការទាំងនេះរួមមានៈ

- កសាងនូវការយល់ដឹងរបស់អាជ្ញាធរស្រុក មន្ទីរនានា ទាក់ទងនឹងសក្តានុពលនៃវារីវប្បកម្មសមុទ្រជាប្រភពនៃការចិញ្ចឹមជីវិតដោយនិរន្តរភាពនៅតំបន់ជនបទ ។
- រកនូវ "មនុស្សគោលដៅ" ដើម្បីធ្វើជាប្រឹក្សាដល់កសិករលើការរៀបចំយុទ្ធសាស្ត្រប្រើប្រាស់ធនធាននៅថ្នាក់មូលដ្ឋាន
- ជំរុញឱ្យឆាប់រហ័សលើផ្នែកនាយកដ្ឋានជលផលរដ្ឋ និង នាយកដ្ឋានដែលពាក់ព័ន្ធដើម្បីជួយកសិករឱ្យចុះបញ្ជីកសិដ្ឋានរបស់ខ្លួនទាក់ទងនឹងលិខិតបទដ្ឋានរបស់អាជ្ញាធរវារីវប្បកម្ម[1]

## បញ្ហាក្នុងការអភិវឌ្ឍន៍វារីវប្បកម្មសមុទ្រនៅប្រទេសឥណ្ឌា

ការអភិវឌ្ឍន៍វារីវប្បកម្មសមុទ្រនៅប្រទេសឥណ្ឌាគឺត្រូវបានរារាំងដោយជំលោះក្នុងចំណោមកសិករ និង ប្រធានសហគមន៍ខ្វះសមត្ថភាព ។ គំរោងដ៏ជោគជ័យនៃការធ្វើជាតូបនីយកម្មនៃធនាគារនៅក្នុងវិស័យកសិកម្ម ដូចជា ឥណទានខ្នាតតូច មិនទាន់ទទួលបានការចាប់អារម្មណ៍ពីផ្នែកវារីវប្បកម្មនៅឡើយ ។ ជាទូទៅជំលោះគឺមានទៅលើកម្មសិទ្ធដីធ្លី ប្រពន្ធ័ប្រឡាយបញ្ចេញបញ្ចូលទឹក ពេលវេលានៃការបញ្ចូល និង រំដោះទឹកចេញ និង សិទ្ធលើការប្រើប្រាស់ដីដែលនៅទំនេរ ។ ខ្វះនូវចំណេះដឹងបច្ចេកទេស និង កិច្ចខិតខំរបស់ស្ថាប័ន និង សេវាកម្មផ្សព្វផ្សាយមិនបានល្អ ក៏ជាបញ្ហាចំបង ដូចជាគោលនយោបាយជួលដីធ្លីជាដើម ។ តំលៃជួលខ្ពស់ និង មានរយៈពេលខ្លីក៏ជាបញ្ហារារាំងដល់ការអភិវឌ្ឍន៍ឆាប់រហ័សផងដែរ ។ ស្លាកស្នាមអយុត្តិធម៌នៅក្នុងសង្គមដែលភ្ជាប់ទៅនឹងវារីវប្បកម្ម ការបំផ្លាញស្រះ ខ្វះសំភារៈបំពាក់បំប៉ននៅថ្នាក់មូលដ្ឋាន ហើយពេលខ្លះការចូលរួមរបស់ស្ត្រីតិចតួចនៅក្នុងវិស័យនេះក៏ជាមូលហេតុនៃការយឺតយ៉ាវនៃការរីកចំរើនផងដែរ ។

## ការចាំបាច់នៃកិច្ចខិតខំប្រឹងប្រែងរួមគ្នា

ស្ថិតក្រោមការផ្លាស់ប្តូរនៃទិដ្ឋភាពទូទៅរបស់អង្គការពាណិជ្ជកម្មពិភពលោក វារីវប្បកម្មនៅប្រទេសឥណ្ឌាទទួលបានការរីកចំរើនដែលបានមកពីការឆ្នៃប្រឌិតយុទ្ធសាស្ត្រផលិតកម្មដូចជា កិច្ចសន្យាជាមួយវារីវប្បករខ្នាតតូច ដែលអាចជួយបង្កើនផលិតផលសរុប ។ កិច្ចសន្យាជាមួយវារីវប្បករខ្នាតតូចអាចផ្តល់នូវលទ្ធភាពក្នុងការធ្វើវារីវប្បកម្មសមុទ្រ ដែលភាគច្រើននៃអ្នកចិញ្ចឹមបង្គា

[1] អាជ្ញាធរវារីវប្បកម្មត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលឥណ្ឌាក្រោមឧបសម្ព័នទី៣ (៣) នៃការការពារបរិស្ថាន ប្រកាសឱ្យប្រើនៅឆ្នាំ១៩៨៦ដើម្បីដោះស្រាយបញ្ហាដែលបណ្តាលមកពីការចិញ្ចឹមបង្គានៅតំបន់សមុទ្រ ។ ពត៌មានលំអិតសូមមើល < www.aquaculture.tn.nic,in >

គឺជា " កសិករដែលមានធនធានមានកេរ្តិ៍ " ចិញ្ចឹមលើផ្ទៃទឹកតិចជាង ១ ហិចតា " ។ គោលការណ៍នៃ កិច្ចសន្យាជាមួយវារីវប្បករខ្នាតតូចគឺការរៀបចំ " ទិញយកវិញ " ។ វារីវប្បករខ្នាតតូចយល់ឃើញថាការរៀបចំរបៀបនេះមានការសមស្របដោយសារតែធនធានដាក់បញ្ចូល (Input) ដែលរួមបញ្ចូលទាំងការណែនាំពីបច្ចេកទេស ហើយផលិតផលត្រូវបានគេប្រមូលទិញនៅកសិដ្ឋានតែម្តង ។

ត្រូវបង្កើនការយល់ដឹងជាបន្ទាន់នៅលើផ្នែកអាជ្ញាធរស្រុកពីសក្តានុពលនៃវារីវប្បកម្មសមុទ្រ ។ គួរអប់រំដល់ នាយកដ្ឋានដែលពាក់ពន្ធ័នឹងប្រាក់ចំណូល កសិកម្ម ធារាសាស្ត្រ សាធារណៈការ អគ្គិសនី ធនាគាមូលដ្ឋាន ធនាគាជាតិសំរាប់កសិកម្ម និង អភិវឌ្ឍន៍ជនបទ និង ក្រុមហ៊ុនធានារ៉ាប់រង ពីសេចក្តីត្រូវការផ្សេងៗនៃវារីវប្បកម្មសមុទ្រ ។ ការលើកកំពស់ការយល់ដឹងដើម្បីអប់រំអ្នកឯកទេសទាំងនេះមិនចាំបាច់ធ្វើពីលើមកក្រោមទេ ។ គួរធ្វើទំនាក់ទំនងជាមួយប្រធានរដ្ឋបាលនៃទីភ្នាក់ងារទាំងនេះដើម្បី កំណត់ និង បំពាក់បំប៉នដល់អ្នកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គេ ដែលមានចំណង់ចំណូលចិត្តធ្វើការផ្សព្វផ្សាយ ។ អ្នកផ្សព្វផ្សាយថ្នាក់ភូមិមិនសុទ្ធតែជាជំរើសដ៏ល្អនោះទេ ។

**សារៈសំខាន់នៃ "មនុស្សគោលដៅ "** (Focus Person)

ការសិក្សានៅក្នុង ២ ស្រុក យើងរកឃើញថា មានមនុស្សតិចតួចប៉ុណ្ណោះដែលសកម្មចូលរួមនៅក្នុងសកម្មភាពវារីវប្បកម្មសមុទ្រ ។ ពួកគេធ្វើការនៅនាយកដ្ឋានជលផល ឬ សាស្ត្រាចារ្យនៅសកលវិទ្យាល័យដែលបានផ្តល់មតិលើសហគមន៍ ឧទា. លោក Panchayat ( ប្រធានរដ្ឋបាលថ្នាក់មូលដ្ឋាន) ។ ពួកគេមិនបានដឹងពីចំណេះដឹងដែលពួកគេមាន នឹង ការរួមចំណែករបស់ពួកគេដល់ភូមិ និង ស្រុកទេ បើសិនជាពួកគេមិនត្រូវបានគេផ្តល់ឱ្យនូវការបំពាក់បំប៉ន ការអនុវត្តន៍ និង ពីសារៈសំខាន់ឱ្យបានត្រឹមត្រូវ ។ ការធ្វើការងាររបស់ពួកគេនៅពេលនោះគឺជួបប្រទះការលំបាកដោយបទបញ្ញត្តទាំងឡាយដែលត្រូវតែគោរព ហើយត្រូវតែមានវត្ត-មាននៅក្នុងការិយាល័យ ថ្វីត្បិតតែគេចង់ធ្វើការនៅមូលដ្ឋានក៏ដោយ ។ ការរួមវិភាគទានរបស់ពួកគេទៅលើការអភិវឌ្ឍន៍វិស័យវារីវប្បកម្មសមុទ្រនឹងមានទំហំកាន់តែធំ បើសិនជាគ្មានអង្គការក្រៅរដ្ឋាភិបាលបំពាក់បំប៉ននៅលើវិស័យវារីវប្បកម្មសមុទ្រនេះ ។ តួនាទីរបស់មនុស្សទាំងនេះអាចធ្វើឱ្យកសិករទទួលបាននូវការជឿជាក់ និងជួយពួកគាត់ក្នុងការចុះបញ្ជីកសិដ្ឋានជាមួយអាជ្ញាធរវារីវប្បកម្ម ។ មនុស្សទាំងនេះមាននៅក្នុងភូមិ ឬ ឃុំរួចទៅហើយ ។ ពួកគេអាចត្រូវបានគេប្រើប្រាស់ដើម្បីកសាងនូវទំនុងចិត្តរបស់អ្នកភូមិនៅក្នុងតំបន់ដែលពួកគេមានឥទ្ធិពល ។ ជាអ្នកដឹកនាំ និង មានចរិតលក្ខណៈជាម្ចាស់ស្រុក ពួកគេមានលក្ខណៈបន្ថែមទៀតគឺការទំនាក់ទំនងជាបុគ្គលជាមួយនាយកដ្ឋានដែលពាក់ពន្ធ័ដែលអាចរៀបចំនូវទិសដៅ និង ការអភិវឌ្ឍន៍វារីវប្បកម្មប្រកបដោយនិរន្តរភាព ។

**សហគ្រិន និង អ្នកគ្រប់គ្រងធនធាន**

វារីវប្បកម្មសមុទ្រ ដូចជាសកម្មភាពសេដ្ឋកិច្ចដ៏ទៃទៀតដែរ គឺជាដំណើរការនៃចង្វាក់ផលិតកម្ម ។ ការកែទំរង់ដីធ្លី លិខិតបទដ្ឋានប្រាក់ចំណូល និង ការចាត់ថ្នាក់គឺជាការទុកដាក់របស់រដ្ឋ ចំណែកឯកំលាំងពលកម្មដែលគ្មានជំនាញគឺជាបញ្ហាក្នុងមូលដ្ឋានក្នុងវិស័យវារីវប្បកម្មសមុទ្រ ។ ជំនាញនៅតាមសហគ្រិនគឺមានរួចទៅហើយជាពិសេសលើផ្នែកកែច្នៃ ។ ធនធានស្ថាប័ន និង មិនមែនស្ថាប័នគឺជាដំណើរការនៃការអប់រំ លទ្ធភាព និង គំនិតចង់វិនិយោគ ។ ដូច្នេះហើយបានជាវិស័យនេះត្រូវការការគាំទ្រពីស្ថាប័នពាក់ពន្ធ័ទាំងអស់ ។

វារីវប្បកម្មសមុទ្រជំនះបាននូវកិត្តិសព្ទមិនល្អនៅក្នុងប្រទេសឥណ្ឌា។ ការកើនឡើងនូវគំនិតអវិជ្ជមានពីមហាជននៅក្នុងឆ្នាំ ១៩៩០ បានបន្ទុចបង្អាក់ដល់ការវាស់វែងនូវការយល់ដឹងពីវារីវប្បកម្មសមុទ្រ ជាពិសេសនៅភូមិដាច់ស្រយាល។ ការគ្រប់គ្រងបានត្រឹមត្រូវ បានធ្វើឱ្យទិន្នផលទទួលបានស្ថេរភាព និង អាចការពារបាននូវការកើតឡើងនៃជំងឺ។ ការឆាប់ទទួលយករបស់សហគមន៍បាន បង្ហាញនូវលទ្ធភាពរបស់វិស័យនេះក្នុងការធានាកិត្តិសព្ទរបស់ផលិតផលក្នុងរយៈពេលយូរអង្វែង។

**ឯកសារយោង**

Krishnan M, Birthal, Pratap S, Ponnusamy, K, Kumaran, M and Singh, H 2001 *An Economic Evaluation of Brackishwater Aquaculture Systems in India*. Final Report. ICAR-AP Cess Fund Project, Central Institute of Brackishwater Aquaculture, Chennai, and National Centre for Agricultural Economics and Policy Research, New Delhi.

*Dr M Krishnan is a Senior Scientist (Economics) at the Central Institute of Brackishwater Aquaculture in Chennai, India. He can be reached at < mahadevak@hotmail.com > or < emkay1957@yahoo.co.in >. Dr Pratap S Birthal is a Senior Scientist (Economics) at the National Centre for Agricultural Economics and Policy Research in New Delhi, India. He can be reached at < psbirthal_ncap@iasri.delhi.nic.in >.*

## ផលិតកម្មកូនត្រីពូជសំរាប់វារីវប្បកម្មនៅភាគអគ្នេយ៏ នៃប្រទេសកម្ពុជា:
## ការធ្វើវិមជ្ឈការ -ផ្លូវដែលត្រូវដើរ?

Olivier Delahaye Gamucci, Graham C Mair Harvey Demaine

### មូលដ្ឋានគ្រឹះ

ត្រីគឺជាផ្នែកមួយយ៉ាងសំខាន់នៃម្ហូបអាហាររបស់ប្រជាជនកម្ពុជា ហើយការផ្គត់ផ្គង់ស្ទើរតែទាំងស្រុងគឺបានមកពីការចាប់។ ប៉ុន្តែ វាត្រូវបានគេធ្វើអាជីវកម្មយ៉ាងខ្លាំងក្លា ដែលមិនអាចផ្គត់ផ្គង់តាមតំរូវការដែលចេះតែកើនឡើងយ៉ាងលឿន។ ហេតុដូច្នេះហើយ វារីវប្បកម្មគឺនឹងដើរតួនាទីសំខាន់នៅលើសុវត្ថិភាពស្បៀងរបស់ប្រទេសនាពេលអនាគត ដែលក្នុងនោះការផ្គត់ផ្គង់កូនត្រីដែលមាន គុណភាពល្អជាកត្តាសំខាន់មួយ។ ជាទូទៅ ហេដ្ឋារចនាសម្ព័នរបស់ប្រទេសកម្ពុជាគឺមានភាពខ្វះខាត កសិករមានលទ្ធភាពធ្វើដំណើរ នៅមានកំរិត និង បណ្តាញលក់ដូរច្រើនមានតែនៅតំបន់ដែលមានការអភិវឌ្ឍន៏។ កសិករត្រូវការកូនត្រីពូជដែលអាចរកបាននៅក្នុង មូលដ្ឋាន ហើយឱ្យស្របនឹងពេលវេលាដែលត្រូវស្តុកនៅក្នុងស្រះ។ ការរកបាននូវប្រភេទកូនត្រីដែលសមស្រប និង គុណភាពល្អ (ការគ្រប់គ្រងបានល្អ និង មានសេនេទិចល្អ) ក៏ជាបញ្ហាដែលទទួលនូវការចាប់អារម្មណ៏ផងដែរ។ សព្វថ្ងៃនេះការផ្គត់ផ្គង់កូនត្រីពូជ នៅក្នុងប្រទេសកម្ពុជាគឺនៅតែពឹងផ្អែកលើកន្លែងអាងភ្ញាស់ខ្នាតធំដែលមានចំនួនតិចតួច និងស្ថិតនៅតំបន់ដែលមានការអភិវឌ្ឍន៏ ជាមជ្ឈការ ប៉ុន្តែគ្មានការអភិវឌ្ឍន៏ផ្នែកប្រពន្ឋ័ចែកចាយ។ ដូច្នេះ ការផ្គត់ផ្គង់កូនត្រីពូជនៅតំបន់ជនបទគឺនៅតែមានភាពខ្វះខាត។

### បរិបទនៃការសិក្សា

ដើម្បីរកនូវឱកាស និង បញ្ហានៃផលិតកម្មកូនត្រីពូជនៅកម្ពុជា ការអង្កេតមួយត្រូវបានធ្វើឡើងចាប់ពីខែ មករា ដល់ខែ មេសា ឆ្នាំ ២០០២ ក្នុងខេត្ត ៤ នៅភាគអគ្នេយ៏នៃប្រទេសកម្ពុជា។ ការសិក្សាបានផ្តោតជាសំខាន់លើការអភិវឌ្ឍន៏ប្រពន្ឋ័ផលិតកម្មកូនត្រីពូជ ដោយពិនិត្យលើផ្នែកបច្ចេកទេស ស្ថាប័ន ហេដ្ឋារចនាសម្ព័ន សេដ្ឋកិច្ច និង បណ្តាញ។

### ស្ថានភាពនៃប្រពន្ឋ័: ផ្នែកមួយនៃការធ្វើវិមជ្ឈការ

ការសិក្សាបានបង្ហាញថា អ្នកផលិតកូនត្រីពូជមានលក្ខណៈខុសៗគ្នាដែលអាចចាត់ថ្នាក់ជា ៤ ប្រភេទ រាប់ទាំងរបស់រដ្ឋាភិបាល ឬ អ្នកផ្តល់ជំនួយ ដល់អ្នកផលិតកូនត្រីពូជខ្នាតតូច។ ការពិនិត្យទៅលើបញ្ហាសំខាន់ៗបានបង្ហាញថា ការធ្វើប្រពន្ឋ័មជ្ឈការសាធារណៈ គឺមិនមាននិរន្តភាពផ្នែកហិរញ្ញវត្ថុ មិនអាចផ្គត់ផ្គង់កូនត្រីពូជដល់តំបន់ដែលនៅឆ្ងាយៗ ហើយជួនកាលបានរារាំងដល់ការអភិវឌ្ឍន៏ វិស័យឯកជនតាមរយៈការប្រកួតប្រជែង។ ការធ្វើវិមជ្ឈការលើប្រពន្ឋ័នេះគឺអាចដោះស្រាយនូវស្ថានភាពបច្ចុប្បន្ននៅតំបន់ជនបទ ហើយឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់កសិករនៅជនបទ។





*ផលិតកម្មកូនត្រីពូជជាលក្ខណៈខ្នាតធំនៅ ទូលក្រសាំង អនុវត្តដោយកម្មវិធី (នៅខាងឆ្វេងដៃ)និង កន្លែងភ្ញាស់កូនត្រីជាលក្ខណៈគ្រួសារដែលគ្រប់គ្រងដោយកសិករនៅតំបន់ជនបទ (នៅខាងស្តាំដៃ)*

ផ្នែកផលិតកម្មកូនត្រីពូជខ្នាតតូចគឺនៅមានភាពក្មេងខ្ចីនៅឡើយ ហើយតែងតែប្រើនូវសំភារៈ និង ហេដ្ឋារចនាសម្ព័ន្ធដែលមានកំរិត ប៉ុន្តែគ្រប់គ្រងទទួលបានជោគជ័យ។ ផ្នែកនេះគឺមានការច្នៃប្រឌិត ទន់ភ្លន់ និង អាចផ្តល់នូវការផ្សព្វផ្សាយដល់កសិករ។ ការខ្វះខាតការឧបត្ថម្ភបច្ចេកទេស និង ថវិការ រួមជាមួយនឹងការខ្វះខាតនូវធនធានដាក់បញ្ចូល គឺជាបញ្ហាចំបងរបស់អាងភ្ញាស់នៅជនបទ។ ការគ្រប់គ្រងសេនេទិចរបស់ត្រីមេពូជគឺមិនទាន់បានសមស្របគ្រប់អ្នកផលិតទាំងអស់ ដោយរួមបញ្ចូលទាំងអ្នកផលិតខ្នាតធំ បញ្ហានៃការថយចុះគុណភាពសេនេទិចដែលបណ្តាលមកពី ការផ្លាស់ប្តូរនូវសេនេទិច (Genetic drift) ការបង្កាត់មេពូជដដែលៗ (Inbreeding) និង ការឆ្លងនូវហ្សែនពីអ៊ីប្រ៊ីតមួយ (Hybrid introgresion)ហើយដែលប៉ះពាល់ដល់ការចិញ្ចឹមនាពេលអនាគត ។ អាងភ្ញាស់របស់អង្គការក្រៅរដ្ឋាភិបាល និង សាធារណៈផលិតបានកូនត្រីច្រើនជាងអាងភ្ញាស់ខ្នាតតូច ប៉ុន្តែអាងភ្ញាស់ទាំងនេះគឺជាមុខសញ្ញានៃការប្រកួតប្រជែង ដែលតែងតែប្រមូលផ្តុំនៅតំបន់តូច ហើយជួបប្រទះនូវតំរូវការថយចុះ ឬ នៅថេរ។ ផ្ទុយមកវិញ អ្នកផលិតកូនត្រីពូជខ្នាតតូចបែរជាទទួលបាននូវតំរូវការកូនត្រីកើនឡើង ដោយមានការប្រកួតប្រជែងតិចតួច ហើយដោយសារការអភិវឌ្ឍន៍វារីវប្បកម្មកើតមាននៅតែនៅតំបន់ជនបទ។

**ការធ្វើមជ្ឈការ និង វិមជ្ឈការយុទ្ធសាស្រ្តផលិតកម្មកូនត្រីពូជ**

នៅដំណាក់កាលតំបូងនៃការអភិវឌ្ឍន៍វារីវប្បកម្ម ដោយខ្វះខាតនូវធនធាន និង ជំនាញ ការធ្វើមជ្ឈការយុទ្ធសាស្រ្តផលិតកម្មកូនត្រីគឺមានលក្ខណៈសមស្រប។ សព្វថ្ងៃនេះ វាបានបង្ហាញច្បាស់ថា កសិករនៅប៉ែកអគ្នេយ៏នៃប្រទេសកម្ពុជាទទួលបាននូវផលប្រយោជពីការធ្វើវិមជ្ឈការនៃការផ្គត់ផ្គង់។ ការផ្លាស់ប្តូរនូវយុទ្ធសាស្រ្តបែបនេះត្រូវបានគេធ្វើដោយទទួលជោគជ័យនៅបណ្តាប្រទេសអាស៊ីជាច្រើន ដែលភាគច្រើនសហគ្រិនឯកជនឥឡូវនេះជាអ្នកផលិតកូនត្រី។ ពីមួយថ្ងៃទៅមួយថ្ងៃ ដោយមានការរីកចំរើនផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងទីផ្សារត្រីនៅជនបទ តំរូវការកូនត្រីនឹងកើនឡើង និង មានសារៈសំខាន់ដែលធ្វើឱ្យកើតមាននៅអ្នកផលិតកូនត្រីជាលក្ខណៈពាណិជ្ជកម្ម និង ការបង្កើតនូវបណ្តាញឈ្មួញកណ្តាល។ ស្ថិតនៅក្រោមការវិវត្តន៏ប្រព័ន្ធផ្គត់ផ្គង់កូនត្រីរបៀបនេះ អាងភ្ញាស់ទ្រង់ទ្រាយធំៗរបស់រដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាលអាចផ្លាស់ប្តូរតួនាទីរបស់ខ្លួនពីអ្នកផ្គត់ផ្គង់កូនត្រីសំខាន់ ទៅជាអ្នកធានានូវការរកបាននូវកូនត្រី និង ត្រីមេពូជដែលមានគុណភាព។

**ការធ្វើវិមជ្ឈការការផ្គត់ផ្គង់កូនត្រី**

ការធ្វើវិមជ្ឈការការផ្គត់ផ្គង់កូនត្រីអាចសំរេចបានតាមរយៈការលើកកំពស់ការអភិវឌ្ឍន៍បណ្តាញចែកចាយទ្រង់ទ្រាយតូចទូទាំងប្រទេស (សូមមើលគំនូសបំព្រួញ)។ ធនធានរបស់អាងភ្ញាស់សាធារណៈ និង អង្គការក្រៅរដ្ឋាភិបាលគួរតែត្រូវបានគេយកទៅប្រើប្រាស់ដើម្បីជួយដល់ផ្នែកឯកជន ជៀសជាងរារាំងវា តាមរយៈការប្រកួតប្រជែងដោយផលិតកូនត្រីលើស។ សកម្មភាពផ្សព្វផ្សាយពីមន្ត្រីខេត្ត និង អង្គការក្រៅរដ្ឋាភិបាលគួរតែផ្តោតជាសំខាន់លើអ្នកផលិតកូនត្រីខ្នាតតូច ដោយផ្តល់នូវការបំពាក់បំប៉នលើផ្នែកផ្សេងៗនៃវារីវប្បកម្ម និង ការផ្ទេរបច្ចេកវិទ្យា ដើម្បីកសាងនូវខ្សែសង្វាក់ឧបត្ថម្ភពីអ្នកផលិតរហូតដល់អតិថិជនរបស់ខ្លួន។ ប៉ុន្តែវាអាចធ្វើទៅបានបើសិនជាអ្នកធ្វើគោលនយោបាយមានការសំរេចចិត្ត និង យុទ្ធសាស្រ្តច្បាស់លាស់ ដែលតំរូវឱ្យមានការពិគ្រោះយោបល់ជាមួយអ្នកជាប់ពាក់ពន្ធ័ក្នុងការអភិវឌ្ឍន៏វិស័យវារីវប្បកម្មនៅកម្ពុជាទាំងអស់។




កសាងបណ្តាញវិមជ្ឈការកូនត្រីពូជខ្នាតតូច (ពណ៌ខៀវ)

*Olivier Delahaye Gamucci is with SEAFDEC Secretariat, Bangkok, Thailand, and was formerly an AIT masters student. Graham C Mair and Harvey Demaine are with the Asian Institute of Technology, Bangkok, Thailand. The authors can be reached through Olivier Gamucci at* <odega@seafdec.org> *or through Graham Mair at* <gcmair@ait.ac.th>.

# ពត៌មានពីទស្សនាវដ្ដីរបស់ STREAM


បោះពុម្ពដោយ STREAM- Support to Regional Aquatic Resources Management
Network of Aquaculture Centres in Asia-Pacific (NACA) Secretariat
Suraswadi Building
Department of Fisheries Compound
Kasetsart University Campus
Ladyao, Jatujak, Bangkok 10903
Thailand



ក្រុមអ្នកបោះពុម្ពផ្សាយ

Graham Haylor, នាយកនៃគំរោង STREAM

Le Thanh Luu, អ្នកសំរបសំរួលជាតិនៃគំរោង STREAMនៅវៀតណាម

William Savage, អ្នកជំនាញការខាងទំនាក់ទំនងនៃគំរោង STREAM

Sonia Seville, អ្នកសំរបសំរួលជាតិនៃគំរោង STREAMនៅហ្វីលីពីន

Thay Somony, អ្នកសំរបសំរួលជាតិនៃគំរោង STREAMនៅកម្ពុជា


## គោលបំណង

ទស្សនាវដ្ដីរបស់ STREAMបោះពុម្ពរៀងរាល់ត្រីមាសដើម្បីលើកកំពស់ការចូលរួម, ទំនាក់ទំនង, និង គោលនយោបាយដែលជួយដល់ជីវភាពរស់នៅអ្នកប្រើប្រាស់ធនធានវារិជាតក្រីក្រក្នុងតំបន់អាស៊ីប៉ាស៊ីភិច និង កសាងទំនាក់ទំនងក្នុងវិស័យគ្រប់គ្រងធនធានវារិជាត និង ផ្នែកផ្សេងទៀតនៅក្នុងតំបន់។ ទស្សនាវដ្ដីរបស់ STREAMមានអត្ថបទដែលទាក់ទងនឹងប្រជាជនដែលការចិញ្ចឹមជីវិតរបស់ពួកគេពឹងផ្អែកលើធនធានជលផល ជាពិសេសប្រជាជនដែលមានធនធានតិចតួច អ្នកអនុវត្ត រដ្ឋាភិបាល មិនមែនរដ្ឋាភិបាល និង អន្តរជាតិ ដែលធ្វើការជាមួយពួកគេក្នុងសហគមន៍។ បញ្ហាមានដូចជា: ការរៀនសូត្រ, ការគ្រប់គ្រងជំលោះ, បច្ចេកវិទ្យាទំនាក់ទំនង និង ពត៌មាន, ការគ្រប់គ្រងធនធានវារិជាត, ច្បាប់, ការចិញ្ចឹមជីវិត, យិនឌ័, ការចូលរួម, អ្នកជាប់ពាក់ពន្ធ័, គោលនយោបាយ និង ទំនាក់ទំនង។

គោលបំណងសំខាន់មួយផ្សេងទៀតរបស់ទស្សនាវដ្ដី STREAMគឺផ្ដល់ឱកាសឱ្យបញ្ចេញសំលេងដែលកំរមានដើម្បីឱ្យគេបានលឺ និង មានតំណាងនៅក្នុងវិជ្ជាជីវបោះពុម្ពដែលមានបន្ថិចបន្តួចនៅក្នុងស្ថាប័នរៀនសូត្រ។ មាតិកាក្នុងទស្សនាវដ្ដី មិនត្រូវយកទៅដើម្បីបញ្ជាក់ពីទស្សនៈនៃអង្គការ ឬ ភ្នាក់ងារណាមួយទេ ប៉ុន្តែវាគ្រាន់តែជាគំនិតនៃ

មនុស្សម្នាក់ៗដោយផ្អែកលើបទពិសោធរបស់ពួកគេ។ អ្នកនិពន្ធទទួលខុសត្រូវលើមាតិកាអត្ថបទរបស់ពួកគេ ហើយ STREAMទទួលខុសត្រូវលើភាពលំអៀង និង លើសលួសផ្សេងៗ។

## ការចែកចាយ

ទស្សនាវដ្តីរបស់ STREAMអាចរកបានជា ៣ ទំរង់

- ជាទំរង់អេឡិចត្រូនិចដែលត្រូវបានបោះពុម្ព និង ចែកចាយដោយ មណ្ឌលទំនាក់ទំនង STREAM
- ជាទំរង់ដែលអាចរកបាន ហើយទាញមកពី Website របស់ STREAM គឺ www.streaminitiative.org
- ជាឯកសារបោះពុម្ពដែលចែកចាយដោយ លេខាធិការដ្ឋាននៃ បណ្តាញនៃមជ្ឈមណ្ឌលវារីវប្បកម្មក្នុងតំបន់អាស៊ីប៉ាស៊ីភិច

## ការចូលរួមចំណែក

ទស្សនាវដ្តីរបស់ STREAMលើកទឹកចិត្តដល់ការចូលរួមចំណែកជាអត្ថបទដែលទាក់ទងនឹងអ្នកប្រើប្រាស់ធនធានវារីជាត និង មនុស្សដែលធ្វើការជាមួយពួកគេ។ ទស្សនាវដ្តីរបស់ STREAMkក៏ជួយដល់សហការីដែលធ្វើការនៅថ្នាក់សហគមន៍ដើម្បីឱ្យចងក្រងឯកសារពីបទពិសោធរបស់ពួកគេនៅក្នុងទំព័រទាំងនេះ។

អត្ថបទគួរសរសេរជាភាសាអង់គ្លេសដែលងាយយល់ ហើយមិនឱ្យលើសពី ១០០០ ពាក្យ (ប្រហែល ២ ទំព័រ A4)

អ្នកអាចផ្តល់ជាអត្ថបទផ្សេងៗទៅឱ្យលោក William Savage អ្នកបោះពុម្ពផ្សាយ ទស្សនាវដ្តីរបស់ STREAMតាមរយៈ savage@loxinfo.co.th.

ពតិមានបន្ថែមសូមទាក់ទងលោក Graham Haylor នាយកនៃគំរោង STREAM តាមរយៈអ៊ីមែល ghalor@loxinfo.co.th

# ពត៌មានពី STREAM

STREAM (ជួយគាំទ្រការគ្រប់គ្រងធនធានវារីជាតក្នុងតំបន់) ជាគំរោងមួយដែលគ្រោងឡើងក្នុងរយៈ ពេល៥ឆ្នាំនៃ កម្មវិធីការងាររបស់ NACA (បណ្តាញនៃមជ្ឈមណ្ឌល វារីវប្បកម្មក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច) ។

គំរោងមានទិសដៅជួយដល់ទីភ្នាក់ងារ និងស្ថាប័នផ្សេងៗឱ្យៈ

- ប្រើប្រាស់ពត៌មានដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធិភាព
- យល់ឱ្យកាន់តែច្បាស់ថែមទៀតពីជីវភាពរបស់ប្រជាជនក្រីក្រ និង
- អាចឱ្យប្រជាជន ក្រីក្រ ប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនលើគោលនយោបាយ និង ដំណើរការដែលជះឥទ្ធិពល លើជីវិតរបស់ពួកគេ ។

គំរោង នឹងធ្វើការងារនេះតាមរយៈការជួយអភិវឌ្ឍន៏គោលនយោបាយ និង ដំណើរការសំរបសំរួលស្ថាប័ន និង ការកសាងសមត្ថភាពដើម្បីៈ

- រកឱ្យឃើញនូវបញ្ហានៃការគ្រប់គ្រងធនធានវារីជាតដែលជះឥទ្ធិពលទៅលើជីវភាពអ្នកក្រីក្រ
- ពិនិត្យ និង វាយតំលៃលើយុទ្ធវិធីគ្រប់គ្រងផ្សេងៗគ្នា
- ផ្សព្វផ្សាយពត៌មាន
- ធ្វើបណ្តាញនៅក្នុង/រវាងវិស័យ និងរវាងប្រទេស

គំរោងគឺផ្អែកលើភាពជាដៃគូរដែលជាប់ទាក់ទងចាប់តាំងពីការករកើតនូវការរួបរួមជាដៃគូរ (DFID, VSO, FAO) ដែលជួយដល់ (NACA) ។ គំរោងនឹងទទួលយកនូវយុទ្ធវិធីសមស្របមួយដើម្បីសំរេចឱ្យបាននូវ ទំនាក់ទំនងរវាង អ្នកជាប់ពាកលពន្ធ័ទាំងអស់ដែលជាប់ទាក់ទិននិងការគ្រប់គ្រងធនធានវារីជាត និងជួយពួកគេឱ្យរួម ចំណែកក្នុងការរៀបចំ, អនុវត្តន៏ និងការគ្រប់គ្រងគំរោង ។

ការធ្វើការងាររបស់ដៃគូរត្រូវបានសំរបសំរួល នៅក្នុងប្រទេសនិមួយៗតាមរយៈក្រុមសំរបសំរួលជាតិ ដែលរួម មានៈ អ្នកសំរបសំរួលជាតិ (មន្ត្រីជាន់ខ្ពស់ដោយមានការយល់ព្រមជាមួយរដ្ឋាភិបាល) និង អ្នកគ្រប់គ្រងមណ្ឌលទំនាក់ ទំនង (ជាមន្ត្រីដែលធ្វើការពេញម៉ោងហើយជួយឧបត្ថម្ភក្នុងរយៈពេល២ ឆ្នាំដំបូងដោយ STREAM) ហើយភ្ជាប់ ទំនាក់ទំនងជាមួយអ្នកជាប់ពាក់ពន្ធ័ផ្សេងៗ ។ អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនងត្រូវបានគេផ្តល់ឱ្យនូវ Hardware (មាន ដូចជា កុំព្យូទ័រ ម៉ាស៊ីនស្កេន...), Software (កម្មវិធីកុំព្យូទ័រ ដូចជា word, excel..), បំពាក់បំប៉ន, ការជួយឧបត្ថម្ភ ដល់បច្ចេកវិទ្យាពត៌មាន បណ្តាញ និង ធនធានមនុស្ស ហើយភ្ជាប់ជាមួយនឹងអ្នកជាប់ពាក់ពន្ធ័តាមរយៈ Internet ។

ការសំរបសំរួលជាតិគឺអនុវត្តទៅតាម អត្ថបទយុទ្ធសាស្ត្រនៃប្រទេស(CSP) ដោយមានការពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ ហើយធ្វើឡើងដោយអ្នកសំរបសំរួល និង អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនង ដោយមានការពិគ្រោះយោបល់ជាមួយអ្នកជាប់ពាក់ពន្ធ័។ CSP រកឱ្យឃើញនូវបញ្ហា, ផ្តោតលើទំនាក់ទំនងក្នុងតំបន់, ធ្វើសំណើរ និង ធ្វើអាទិភាពសកម្មភាពសំខាន់ និង ស្វែងរកថវិកាសំរាប់អនុវត្តសកម្មភាពនេះពី STREAM និងពីកន្លែងផ្សេងៗទៀត (ដោយមានការជួយជ្រោមជ្រែងពី STREAM)។

ការិយាល័យតំបន់របស់ STREAM (នៅលេខាធិការ NACA ទីក្រុងបាងកក)ដឹកនាំគំរោង, ផ្តល់នូវតួនាទីសំរបសំរួលក្នុងតំបន់, និង មូលនិធិ និង គ្រប់គ្រងបញ្ហាដែលទាក់ទងនឹង ការចិញ្ចឹមជីវិត, ការអភិវឌ្ឍន៍គោលនយោបាយ ទំនាក់ទំនង និង បញ្ហាពិសេសផ្សេងៗទៀត។

ការប្រតិបត្តិរបស់ STREAM គឺជាដំណើរការដដែលៗមួយដែលធ្វើសាកល្បង នៅឆ្នាំទីមួយនៅកម្ពុជា និងវៀតណាមដែលជាកន្លែងមានឱកាសដើម្បីដោះស្រាយនូវភាពក្រីក្រ និងលើកកំពស់អភិបាលកិច្ចល្អ STREAM មានគំរោងពង្រីកទៅបណ្តាប្រទេសផ្សេងៗទៀតនៅពេលទទួលបានបទពិសោធន៍, មេរៀនត្រូវ បានរៀន, ការជះឥទ្ធិពលត្រូវបានដឹង, ហើយថវិកាបន្ថែមត្រូវបានធានា ។ យុទ្ធសាស្ត្រទំនាក់ទំនងរបស់ STREAM គឺមានទិសដៅជួយបង្កើនឥទ្ធិពលដោយធានាថាចំណេះដឹងដែលមានស្រាប់នៅក្នុងតំបន់ និង ជំនាញការ បានជា ពតិមានដល់ដំណើរការផ្លាស់ប្តូរនៅក្នុងតំបន់ ហើយបទពិសោធត្រូវបានចែកចាយទូទាំងតំបន់អាស៊ីប៉ាស៊ីភិច។ ទស្សនាវដ្តីរបស់ STREAM រួមជាមួយវេទិកាពិភាក្សាដែលមាននៅលើ Website គឺជាផ្នែកនៃយុទ្ធសាស្ត្រនេះ។


អាស័យដ្ឋានទំនាក់ទំនងៈ

STREAM National Communications Hub Managers

| | |
|---|---|
| Cambodia | : Sem Viryak, < cfdo@camnet.com.kh > |
| Philippines | : Elizabeth Gonzales < streambfar-phil@skyinet.net > |
| Vietnam | : Nguyen Song Ha < nguyensongha@fpt.vn > |